ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ELECTRICITE DU CAMBODGE

អគ្គិសនីកម្ពុជា
លេខ : ១១៣ អកក.ពខ

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០១៤

**សូមជម្រាបជូន**

**- លោកប្រធាន សាខាអូរបែកក្អម**
**- លោកប្រធាន សាខាវត្តភ្នំ**
**- លោកប្រធាន សាខាចាក់អង្រែក្រោម**
**- លោកប្រធាន អគ្គិសនីខេត្ត គ្រប់ខេត្តចំណុះឱ្យអគ្គិសនីកម្ពុជា**

**កម្មវត្ថុ ៖** ការសហការជាមួយវិទ្យុ ABC

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានសាខា និងលោកប្រធានអគ្គិសនីខេត្តទាំងអស់ជ្រាបថា អគ្គិសនីកម្ពុជាបាននឹងកំពុងសហការជាផ្លូវការជាមួយវិទ្យុ ABC របស់លោកអាចារ្យអេ ដើម្បីទទួលយកការទិតៀនកែលំអរពីសំណាក់អតិថិជនរបស់អគ្គិសនីកម្ពុជា ដែលជាចំណែកមួយយ៉ាងសំខាន់ក្នុងការលើកកំពស់សេវាបំរើអតិថិជនរបស់ខ្លួន។

ដូចនេះអគ្គិសនីកម្ពុជាសូមធ្វើការណែនាំឲ្យលោកប្រធានសាខា និងលោកប្រធានអគ្គិសនីខេត្តទាំងអស់បន្តពង្រឹងការអនុវត្តការងារនៅគ្រប់ផ្នែកទាំងអស់ ជាពិសេសនិយោជិតទទួលទូរស័ព្ទ សំរាប់ការសាកសួរព័ត៌មានបន្តចរន្ត (រៀងរាល់ម៉ោងធ្វើការ) និងសំរាប់សាកសួរព័ត៌មានបច្ចេកទេស(២៤ម៉ោង)។ រាល់ការអាក់ខានការសហការឲ្យបានរហ័សជាមួយវិទ្យុ ABC ត្រូវចាត់ទុកជាកំហុសការងារ ហើយអគ្គិសនីកម្ពុជានឹងចាត់វិធានការរដ្ឋបាលយ៉ាងតឹងរឹងចំពោះនិយោជិតដែលពុំព្រមកែលំអរប្រព័ន្ធការងាររបស់ខ្លួន។

អាស្រ័យដូចបានជម្រាបជូនខាងលើ អគ្គិសនីកម្ពុជាសង្ឃឹមយ៉ាងមុតមាំថា លោកប្រធានសាខា និងលោកប្រធានអគ្គិសនីខេត្តទាំងអស់ នឹងចូលរួមប្រតិបត្តិការណែនាំនេះឲ្យមានប្រសិទ្ធភាពខ្ពស់បំផុត។

សូមលោកប្រធានសាខា និងលោកប្រធានអគ្គិសនីខេត្តទាំងអស់ ទទួលនូវការរាប់អានអំពីខ្ញុំ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ រតនៈ**

**ចម្លងជូន**
- ឯកឧត្តមប្រធានក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា
- អគ្គនាយករង អគ្គិសនីកម្ពុជា
- គ្រប់នាយកដ្ឋាន អគ្គិសនីកម្ពុជា
- គ្រប់ការិយាល័យឯករាជ្យ អគ្គិសនីកម្ពុជា
- វិទ្យុ ABC
- ឯកសារ- កាលប្បវត្តិ